# បណិធានកថា

## ១- ព័ត៌មានទូទៅ

ពាក្យ បណិនធានកថា យើងច្រើនឃើញនៅក្នុងគម្ពីរបាលីព្រះពុទ្ធសាសនាដែលនិយាយពីការតាំងចិត្តរបស់សាវ័កព្រះសម្មាសម្ពុទ្ធដើម្បីប្រារព្ធកិច្ចណាមួយ។ ដាក់ស្តែងនៅក្នុងអដ្ឋកថាខុទ្ទកបាឋៈ សុត្តារម្ភោនៃរតនៈសុត្ត ព្រះអដ្ឋកថាចារ្យបានតែងបណិធានកថាមួយសូត្រឈ្មោះ រតនសុត្តារម្ភោ (ខ្មែរហៅថាធម៌បណិធាន)។ ធម៌បណិធាននៃរតនៈសូត្រ រៀបរាប់អំពីការអធិដ្ឋានរបស់ព្រះអានន្ទត្ថេរ ហើយលោកសូត្រអស់បីយាមក្នុងរាត្រីនៅក្នុងកំផែងក្រុងវេសាលី[1][១]។ ពាក្យថា បណិធានកថា យើងអាចនិយាយឱ្យងាយយល់បានគឺជាពាក្យបួងសួង ពាក្យអធិដ្ឋាន ការតាំងចិត្ត សេចក្តីប្រាថ្នា ដែលកើតឡើងពីកុសលកម្មបច្ចុប្បន្ន ហើយសុំសម្រេចផលបុណ្យនៅអនាគតកាល។ ពាក្យនេះយើងពុំសូវឃើញនៅលើអក្សរថ្មក្តី លើសាស្ត្រា លើក្រាំង និងសំណេរចាស់ៗ ប៉ុន្តែខ្មែរមានអត្ថបទបណិធានតាំងពីសម័យបុរាណមកដល់សម័យបច្ចុប្បន្នតាមរយៈការប្រតិបត្តិសាសនា។ នៅក្នុងការគោរពប្រតិបត្តិសាសនាមនុស្សខ្មែរតែងតែភ្ជាប់និស្ស័យខ្លួនទៅនិងទេព ដែលខ្លួនគោរពបូជាដូចជា ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ និងព្រះពុទ្ធ។ រាល់អំពើបុណ្យកុសលដែលកើតចេញពីៈ ការកសាងទេវស្ថាន ការធ្វើអំណោយ(ស្រែ ចម្ការ ខ្ញុំប្រុសស្រី ដើមឈើស្រូវ អង្ករ គោ ក្របី...) ការស្អាងប្រតិមា ការស្អាងភ្នំខ្សាច់ សាងគម្ពីរ សាស្ត្រា ក្រាំង បំបួសកូន ប្រស់ខ្ញុំ សាងវិហារ សាលា ប្រមេ រនាំងមុខដាច់សុទ្ធតែបួងសួង អធិដ្ឋាន ប្រាថ្នា សុំឱ្យផលបុណ្យជួយសម្រេចតាមបំណងរបស់ខ្លួន។ ពាក្យ បួងសួង អធិដ្ឋាន ប្រាថ្នាគ្មានអ្វីក្រៅពីចង់បានផលតបត្រឡប់មកវិញដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន និងអ្នកដទៃជាអ្នកគុណមកលើខ្លួន។ បច្ចុប្បន្នពាក្យទាំងអស់នេះចាស់ទុំខ្មែរទន្ទេញចេះចាំយ៉ាងរត់មាត់ក្លាយជាកម្រងពាក្យសម្រាប់ឱ្យពរជ័យនៅភូមិស្រុក វត្តអារាមនានា[២]។ ទោះបីជាអត្ថបទ បណិធាន

---

[១] សូមអានៈបុត្ត សំបាន. ប្រជុំភាណវារៈ បាលី-ប្រែនិងសេចក្តីពន្យល់. សៀមរាប. ឆ្នាំ២០១៦

[២] សូមអានៈហែម អេម. កម្រងពរជ័យ. ភ្នំពេញ. ឆ្នាំ២០០០

ប្រើក្នុងវប្បធម៌ខ្មែរយ៉ាងទូលំទូលាយក៏ពិតមែន តែមិនទាន់ចំណងជើងណាមួយបញ្ជាក់ឈ្មោះថា បណិធានកថា ឡើយ។ នៅក្នុងទីនេះយើងអាចកំណត់ប្រភេទអត្ថបទ អធិដ្ឋាន ប្រាថ្នា ជាបណិធានកថាបានដោយសម្អាងទៅលើសាស្ត្រាកណ្ឌព្រះវិភង្គ ខ្សែ២ ចារនៅថ្ងៃសុក្រ ១០កើត ខែបុស្ស ព.ស.២៥០៣ នៅសន្ទឹកខាងចុងក្រោយបន្ទាប់ពីប្រាប់ពីថ្ងៃខែចារចប់ រួចហើយអ្នកចារសរសេរបញ្ជាក់ថា បណិធានកថា ក្នុងសញ្ញខណ្ឌដែលបញ្ជាក់ពីឈ្មោះចំណងជើងអត្ថបទហើយរៀបរាប់សេចក្តីអធិដ្ឋានប្រាថ្នារបស់អ្នកចារ(រូបលេខ១)។ ដូច្នេះធ្វើអាចធ្វើចំណាត់ថ្នាក់កម្រងពាក្យបួងសួង អធិដ្ឋាន ប្រាថ្នា ជាបណិធានកថា។



រូបលេខ១

## ២- ប្រភេទបណិធានកថា

តាមការសង្កេតកន្លងមកយើងអាចបែងចែកប្រភេទបណិធានកថាជាពីរប្រភេទ៖

**សងគុណ៖** ជាធម្មតាគុណទោសក្នុងផ្នត់គំនិតខ្មែរចាត់ទុកជារឿងសំខាន់មួយការប្រាស្រ័យទាក់ទងគ្នាមិនថាក្នុងរង្វង់គ្រួសារឬសង្គម។ ឯការប្រាស្រ័យនោះតែងតែមានកំហុសឆ្គង ការជួយសង្គ្រោះទៅតាមតួនាទីជាម្ដាយ ឪពុក កូន ប្ដី ប្រពន្ធ អ្នកគ្រប់គ្រងប្រទេស ទេព្ដា សត្វ រុក្ខជាតិ។ ប៉ុន្តែការសងគុណក្នុងអត្ថបទបណិធានកថា យើងឃើញការសងគុណមាតាបិតា (រូបលេខ២, ៣,២) គ្រូបាអាចារ្យ(រូបលេខ៥) ប្ដី (រូបលេខ៦)។



រូបលេខ២៖ នេះព្រះនាងលោអ្នកណី អ្នកចើ ធ្វើបុណ្យសងគុណឪពុក។

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



រូបលេខ២៣៖ ធ្វើចេតិយ តបគុណមាតាបិតាក្មេក មាតាបិតាបង្កើត។



រូបលេខ២៤៖ អ្នកឧបាសកអ៊ីវ នាងសិកាជីម សាងក្រាំងព្រះអភិធម្ម៧គម្ពីរ គម្ពីរនាគសេន ធ្វើបុណ្យឆ្លងមមៃ ខែពិសាខ ព.ស.២៤៦២ ដើម្បីឧទ្ទិសផលដល់មាតាបិតា។



រូបលេខ២៥៖ ភិក្ខុវ៉េងបានឆ្លាក់ក្បាច់ត្រីសូល៍ ហោជាង វង់ស្បូវ ឧទ្ទិសផលដល់លោកគ្រូនិងមាតាបិតានិងគ្រូគ្រប់អង្គដែលចេញកម្លាំងធ្វើពីមុនមក។

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

រូបលេខ២៦៖ ឆ្នាំរោងនក្សត្រថ្ងៃអង្គារ១កើត ខែកត្តិកបាហឿងសឺន្ទេ(?)គិតនឹងបងប្អូន សាងនាំងមុខដាច់សងគុណប្តីប្រាថ្នាឱ្យ បានសុខដល់និព្វាន។



**ប្រយោជន៍បរលោក៖** ក្រៅពីប្រយោជន៍បច្ចុប្បន្នមនុស្សរំពឹងចង់បានផលបុណ្យទៅលោកខាងមុខបន្ទាប់ពីខ្លួនស្លាប់ទៅ ហើយសង្ឃឹមផលបុណ្យរបស់ខ្លួនដែលខំកសាងនោះអាចជួយនាំព្រលឹងវិញ្ញាណខ្លួនដាក់ដល់ឋានបរមសុខ សួគ៌ទេវលោក ព្រះនិព្វាន។ ម្យ៉ាងទៀតដើម្បីទ្រទ្រង់សាសនាឱ្យគ្រប់៥០០០វស្សា ឬប្រាថ្នាជាព្រះពុទ្ធ ជាកន្សែរសាពេជ្ជ ជាអរិយបុគ្គលថ្នាក់ណាមួយនៅក្នុងសាសនាព្រះសិអារ្យមេត្រី(រូបលេខ២៧, ៨, ៩)។



រូបលេខ២៧៖ បណិធានកថារបស់លោក ខៅ និងប្រពន្ធធំឈ្មោះនាង ហ៊ូ ប្រពន្ធតូចឈ្មោះនាង ជុំ កំណើតនៅស្រុកសៀមរាបបានគូររឿងព្រះសីជាតុ(ពុទ្ធប្បវត្តិ)ដើម្បីប្រាថ្នាលាបាបកម្មពៀរ លាជម្ងឺទាំងពួង លាភាពអាក្រក់ ប្រាថ្នាសម្បត្តិបរិបូណ៌ក្នុងអនាគតកាល(លំនាំដូចពាក្យលារបស់ជ័យនន្ទក្នុងសិលាចារឹកជ័យនន្ទK.301)។

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



រូបលេខ២៨៖ ការកសាងចេតិយដើម្បីតបគុណមាតាបិតានិងប្រាថ្នាសម្រេចសម្បត្តិបីប្រការ មនុស្ស១ និព្វាន១ ទេវ១។



រូបលេខ២៩៖ អ្នកសាងចេតិយប្រាថ្នាសូមឱ្យចេតិយនេះតាំងគ្រប់៥០០០ព្រះវស្សា។

## ៣- បណិធានកថាក្នុងសិល្បៈខ្មែរ

បណិធានកថាគេចារឹកទុកដើម្បីបញ្ជាក់ពីអំពើបុណ្យដែលបានបំពេញនិងសេចក្តីអធិដ្ឋាន ប្រាថ្នាជាសក្ខីកម្ម។ ជាទូទៅគេចារឹកទុកនៅលើ៖

**សំណង់ស្ថាបត្យកម្ម៖** នៅរាល់សំណង់ពុទ្ធសាសនា កុដិ សាលា ព្រះវិហារ ក្លោងទ្វារ ចេតិយ អ្នកជួយឧបត្ថម្ភកសាងតែងចារឹកបណិធានកថានៅវត្ថុដែលខ្លួនជួយកសាង។ ខាងក្រោមជាបណិធានកថារបស់អ្នកធ្វើរនាំងមុខដាច់ ក្លោងទ្វារ(រូបលេខ១០ដល់១៦)។

អត្ថបទដោយៈ រឹម ទិត្យបញ្ញា



រូបលេខ២១០



រូបលេខ២១១



រូបលេខ២១២



រូបលេខ២១៣



រូបលេខ២១៤



រូបលេខ២១៥

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



រូបលេខ១៦៖ចារលើទ្វាបញ្ឈោតព្រះវិហារ

**ព្រះពុទ្ធបដិមា៖** គេចារឹកបណិធាននៅខាងក្រោយបល្ល័ង្គ ជ្រីខាងលើបល្ល័ង្គ ជ្រីខាងក្រោមបល្ល័ង្គ លើក្បាច់កន្ទុយត្រីខាងមុខបល្ល័ង្គ និងជាយចីវរ(រូបលេខ១៧ដល់២០)។



រូបលេខ១៧



រូបលេខ១៨



រូបលេខ១៩

អត្ថបទដោយៈ រឹម ទិត្យបញ្ញា



រូបលេខ២០៖ព្រះពុទ្ធនិមិត្តអង្គនេះ
លោកគ្រូមហាសង្ឃរាជនាម ចន្ទ ស
សាងនៅព.ស.២៤៩០វស្សា។

**សាស្ត្រា៖** បណិធានកថាដែលរកឃើញច្រើនជាគេគឺនៅលើសាស្ត្រាព្រោះសម័យបុរាណគេនិយមចារសាស្ត្រាដើម្បីកត់ត្រាទុកអត្ថបទមេរៀន រឿងល្បែង ក្រមច្បាប់ ក្បួនទំនាយស្រុកទេស ពង្សាវតារ។ គេចារឹក បណិធានកថា នៅក្របមុខ និងសន្លឹកចុងក្រោយ (រូបលេខ២១, ២២)។



រូបលេខ២១៖ក្នុងរង្វង់ពណ៌លឿងជាបណិធានកថារបស់អ្នកចារ

ប្រភពរូប៖khmermanuscripte.efeo.fr



រូបលេខ២២៖ក្នុងរង្វង់ពណ៌លឿនជាកាព្យបណិធានកថា

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

**គម្ពីរធម៌៖** មកដល់សម័យទំនើបការបោះពុម្ពសៀវភៅការតែសម្បូរបែបទំនៀមចារសាស្ត្រាក៏សឹងតែបាត់បង់មិនសូវអ្នកចាប់អារម្មណ៍ ប៉ុន្តែគំនិតគុណទោស បាបបុណ្យនៅតែមានក្នុងគំនិតជានិច្ច។ ជាក់ស្តែងនៅសម័យប្រែគម្ពីរព្រះត្រៃបិដក មានសៀវភៅធម៌ជាច្រើនមុខ ច្រើនចំណងជើងបានបោះពុម្ពផ្សាយក្រោមការឧបត្ថម្ភអ្នកមានសទ្ធាជាវដាក់វត្តជាបុណ្យកុសល និងជាប្រយោជន៍ដល់សាសនា(រូបលេខ២៤៣, ២៤៤)។




រូបលេខ២៤៣



រូបលេខ២៤៤

ជារួមមកវិញ **បណិធានកថា** ជាពាក្យមានក្នុងគំនិតស្តែងឡើងជាអត្ថបទតាមរយៈសិលាខ្មែរសម័យបុរាណ ជាពាក្យអធិដ្ឋានក្នុងសេចក្តីផ្តើមសាស្ត្រាល្បែងសម័យកណ្តាលចុងអត្ថបទសាស្ត្រាល្បែង និងនៅលើក្របសាស្ត្រាចម្លងនាសម័យទំនើប។ ពាក្យទាំងអស់នោះបានចារឹកទុកនៅលើថ្ម សាស្ត្រា បដិមា និងវត្ថុជាគ្រឿងបូជាចំពោះសាសនាដែលបង្ហាញពីសក្ខីភាពនៃសទ្ធា ជំនឿ និងវត្ថុបំណងពីការកសាង៖ ប្រាសាទ សាស្ត្រា ក្រាំង បដិមា ចេតិយ គំនូរ គម្ពីរធម៌ទាំងនោះដើម្បីប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍បរលោក។

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

# ឯកសារពិគ្រោះ

វង់ សុជាភ៌

ឆ្នាំ២០១២. សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល. ភ្នំពេញ

ហែម អេម

២០០០. កម្រងពរជ័យ. ភ្នំពេញ

ប៊ុត្ត សំបាន

២០១៦. ប្រជុំភាណវារៈ បាលី-ប្រែនិងសេចក្តីពន្យល់. សៀមរាប

យសោធរ

២០១៦-២០១៧. កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ. ភ្នំពេញ

សាស្ត្រាភិមវង្ស

សាស្ត្រាកណ្ឌព្រះវិភង្គ ខ្សែមួយ

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION